# ព្រះអម្ចាស់ទ្រង់ជា ព្រះវរបិតានៃខ្ញុំ

ព្រះអម្ចាស់ ទ្រង់ជាព្រះវរបិតារបស់ខ្ញុំ ទ្រង់បានបង្កើតខ្ញុំ ហើយបានតាំងខ្ញុំឡើង។ [១]

នៅក្នុងសេចក្តីស្រលាញ់ ទ្រង់បានតម្រូវខ្ញុំទុកជាមុន សំរាប់ឲ្យទ្រង់បានទទួលខ្ញុំមកចិញ្ចឹមទុកជាកូនរបស់ទ្រង់ ។ [២]

ព្រះអម្ចាស់អើយ ទ្រង់បានមានព្រះបន្ទូលថា " អញនឹងធ្វើជាព្រះវរបិតាដល់ឯងរាល់គ្នា ហើយឯងរាល់គ្នានឹងធ្វើជាកូនរបស់អញ "។ [៣]

ទ្រង់ជ្រាបនូវរបស់អ្វីដែលខ្ញុំត្រូវការ មុនដែលខ្ញុំសូមទ្រង់ផង។ [៤]

ដូចជាឪពុកមានចិត្តអាណិតអាសូរដល់កូនរបស់ខ្លួន ដូច្នេះទ្រង់មានព្រះហឫទ័យអាណិតអាសូរដល់ខ្ញុំដែរ ។ [៥]

ខ្ញុំមិនមានភាពភ័យខ្លាចទេ ដ្បិតព្រះវរបិតាបានប្រទាននគរស្ថានសួគ៌មកខ្ញុំ ហើយគ្មានអ្នកណាអាចនឹងឆក់វាចេញពីព្រះហស្តរបស់ព្រះវរបិតាខ្ញុំបានឡើយ ។ [៦,៧]

ខ្ញុំមិនបានទទួលនិស្ស័យជាបាវបំរើ ឲ្យត្រូវភ័យខ្លាចទៀតឡើយ គឺបានទទួល និស្ស័យជាកូនវិញ ដោយហេតុនោះបានជាយើងស្រែកឡើងថា ឱអ័ប្បា ព្រះវរបិតាអើយ។ [៨]

| | | | | | |
|---|---|---|---|---|---|
| (១) | ចោទិយកថា | ៣២ : ៦ខ | (៥) | ទំនុកតម្កើង | ១០៣ : ១៣ |
| (២) | អេភេសូរ | ១ : ៥ | (៦) | លូកា | ១២ : ៣២ |
| (៣) | ២កូរិនថូស | ៦ : ១៨ | (៧) | យ៉ូហាន | ១០ : ២៩ |
| (៤) | ម៉ាថាយ | ៦ : ៨ | (៨) | រ៉ូម | ៨ : ១៥ |

**ចោទិយកថា ៣២: ៦៩** តើទ្រង់មិនមែនជាព្រះវរបិតានៃឯង ដែលបានទិញឯងមកទេឬអី ទ្រង់បានបង្កើតឯង ហើយតាំងឯងឡើងផង។

**អេភេសូរ ១: ៥** ពីព្រោះទ្រង់បានតម្រូវយើងរាល់គ្នាទុកជាមុន សំរាប់ឲ្យទ្រង់បានទទួលយើងជាកូនចិញ្ចឹម ដោយសារព្រះយេស៊ូវគ្រីស្ទ តាមបំណងព្រះហឫទ័យទ្រង់។

**២កូរិនថូស ៦: ១៨** អញនឹងធ្វើជាឪពុកដល់ឯងរាល់គ្នា ហើយឯងរាល់គ្នានឹងធ្វើជាកូនប្រុសកូនស្រីដល់អញ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់ដ៏មានព្រះចេស្តាបំផុត»។

**ម៉ាថាយ ៦: ៨** ដូច្នេះ កុំឲ្យអ្នករាល់គ្នាធ្វើដូចគេឡើយ ដ្បិតព្រះវរបិតានៃអ្នក ទ្រង់ជ្រាបនូវរបស់អ្វីដែលអ្នកត្រូវការ មុនដែលអ្នកសូមផង ។

**ទំនុកតម្កើង ១០៣: ១៣** ព្រះយេហូវ៉ាទ្រង់មានព្រះហឫទ័យអាណិត ដល់អស់អ្នកដែលកោតខ្លាចទ្រង់ ដូចជាឪពុកមានចិត្តអាសូរដល់កូនរបស់ខ្លួនដែរ។

**លូកា ១២: ៣២** កុំឲ្យខ្លាច ហ្វូងតូចអើយ ព្រោះព្រះវរបិតានៃអ្នករាល់គ្នា ទ្រង់សព្វព្រះហឫទ័យ នឹងប្រទាននគរមកអ្នករាល់គ្នាពិត ។

**យ៉ូហាន ១០: ២៩** ព្រះវរបិតានៃខ្ញុំ ដែលប្រទានវាមកខ្ញុំ ទ្រង់ធំលើសជាងទាំងអស់ គ្មានអ្នកណាអាចនឹងឆក់វាចេញពីព្រះហស្តរបស់ព្រះវរបិតាខ្ញុំបានឡើយ។

**រ៉ូម ៨: ១៥** អ្នករាល់គ្នាមិនបានទទួលនិស្ស័យជាបាវបំរើ ឲ្យត្រូវភ័យខ្លាចទៀតឡើយ គឺបានទទួលនិស្ស័យជាកូនចិញ្ចឹមវិញ ដោយហេតុនោះបានជាយើងស្រែកឡើងថា ឱអ័ប្បា ព្រះវរបិតាអើយ។

**បកប្រែដោយ: ONE- 2- ONE CAMBODIA**
**អាស័យដ្ឋាន: # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**
**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**
**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**
www.One-2-One world.org
www.derekprince.co.nz PC08